## គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
## សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## ប្រាសាទព្រះវិហារ ថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០

### លក្ខខណ្ឌក្នុងការចូលរួមសិក្ខាសាលា

*១) សេចក្តីអញ្ជើញនេះគឺសម្រាប់តែលោកគ្រូអ្នកគ្រូម្នាក់តែប៉ុណ្ណោះ(គឺមិនអាចផ្ទេរបានទេ) ។*

*២) បើសិនជាលោកគ្រូអ្នកគ្រូមិនបានចូលរួមទេ សូមកុំឲ្យមានអ្នកជំនួសពីព្រោះសិក្ខាសាលាបន្ទាប់នៅឆ្នាំបន្តទៅមកទៀតមានខ្លឹមសារបន្តគ្នា ។*

*៣) បើសិនជាលោកគ្រូអ្នកគ្រូមិនបានចូលរួមលើកនេះ សិក្ខាសាលាលើកក្រោយនឹងមិនត្រូវបានអញ្ជើញឲ្យចូលរួមទៀតទេ ដោយយោងទៅលើមូលហេតុរៀបរាប់ខាងលើ ។*

*៤) សូមសរសេរដោយដៃអំពីរឿងរ៉ាវអំពីភូមិ ដែលលោកគ្រូអ្នកគ្រូកំពុងបង្រៀនតាមការណែនាំឲ្យបានយ៉ាងតិច ១០ទំព័រ និងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាអោយបានមុនថ្ងៃ២៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។*

*៥) មជ្ឈមណ្ឌលឯកសារកម្ពុជាចេញសាហ៊ុយធ្វើដំណើរទៅមក និងរៀបចំកន្លែងស្នាក់នៅនិងអាហាររយៈពេលបីថ្ងៃ គឺថ្ងៃទី២៤ ថ្ងៃទី២៥ និងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០ ជូនលោកគ្រូអ្នកគ្រូ ។*

### ការណែនាំក្នុងការសរសេរ

*១) រៀបរាប់ប្រវត្តិភូមិអាចជាប្រវត្តិជាក់ស្តែងនិងរឿងព្រេងដែលទាក់ទងនឹងភូមិដែលទាក់ទងទៅនឹងឈ្មោះភូមិ ។*

*២) រៀបរាប់ពីស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ភូមិក្នុងសម័យសង្គមរាស្ត្រនិយម ។*

*៣) រៀបរាប់ពីប្រវត្តិភូមិក្នុងសម័យខ្មែរក្រហម សូមបញ្ចូលចំណុចដូចខាងក្រោម៖*

- *តើប្រជាជនចាស់នៅក្នុងភូមិត្រូវជម្លៀសទៅណា? ប្រជាជនថ្មីនោះជម្លៀសមកពីណាខ្លះ?*
- *តើមានការសម្លាប់មនុស្សយ៉ាងដូចម្តេចខ្លះ?*
- *តើមានរណ្តៅសពចំនួនប៉ុន្មាន? ហើយនៅទីណាខ្លះ?*
- *តើចំនួនអ្នកស្លាប់នៅក្នុងភូមិក្នុងសម័យខ្មែរក្រហមមានប៉ុន្មាននាក់តាមការសន្និដ្ឋាន?*
- *សូមរៀបរាប់ពីប្រភេទការងារដែលខ្មែរក្រហមចាត់ឲ្យអ្នកភូមិធ្វើ រៀបរាប់ពីថ្នាក់ដឹកនាំភូមិ (ឈ្មោះនិងភេទ) ហើយភូមិនោះស្ថិតនៅក្នុងតំបន់ និងភូមិភាគណា?*

*៤) រៀបរាប់ពីការកសាងភូមិឡើងវិញក្រោយសម័យខ្មែរក្រហម(ចាប់ពីឆ្នាំ១៩៧៩)៖*

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

- ការបើកបង្រៀនឡើងវិញនៃសាលាដែលលោកគ្រូអ្នកគ្រូបង្រៀនក្រោយសម័យខ្មែរក្រហម
- រៀបរាប់ត្រួសៗអំពីប្រវត្តិវិទ្យាល័យក្នុងភូមិ ។

៥) បើមានព័ត៌មានបន្ថែមផ្សេងទៀតលើចំណុចទាំងអស់ខាងលើសូមបន្ថែម ។

ព័ត៌មានបន្ថែមសូមទាក់ទង អេង កុកថាយ តាមទូរស័ព្ទលេខ ៖ ០១២ ៩៥ ៥៨ ៥៨